**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * *

# ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលឯកឧត្តម Amjad Ali Sher ឯកអគ្គរដ្ឋទូតប៉ាគីស្ថានប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា

នៅព្រឹកថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យ**ឯកឧត្តម** Amjad Ali Sher ឯកអគ្គរដ្ឋទូតសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថានចូលជួបសម្តែងការគួរសម និងជម្រាបលានៅទីស្តីការក្រសួងក្នុងឱកាសដែលឯកឧត្តមចប់អាណត្តិបេសកកម្មការទូតនៅកម្ពុជា។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវការអបអរសាទរចំពោះឯកឧត្តមឯកអគ្គរដ្ឋទូតដែលបានបញ្ចប់បេសកកម្មការទូតរយៈពេលជាង៦ឆ្នាំប្រកបដោយជោគជ័យនៅកម្ពុជា។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តមឯកអគ្គរដ្ឋទូតដែលបានរួមចំណែកយ៉ាងសំខាន់ធ្វើឱ្យទំនាក់ទំនង និងកិច្ចសហប្រតិត្តិការរវាងកម្ពុជា និងប៉ាគីស្ថានកាន់តែទូលំទូលាយ និងស៊ីជម្រៅបន្ថែមទៀត។

ជាការឆ្លើយតប **ឯកឧត្តម ឯកអគ្គរដ្ឋទូត** បានសម្តែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជាចំពោះកិច្ចសហការយ៉ាងល្អ ជាពិសេសក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលរួមចំណែកធ្វើឲ្យការបំពេញបេសកកម្មការទូតរបស់ឯកឧត្តមនៅកម្ពុជា ទទួលបានជោគជ័យ។ **ឯកឧត្តម ឯកអគ្គរដ្ឋទូត** បានមានប្រសាសន៍ថា ក្នុងអំឡុងពេលបំពេញការងារនៅកម្ពុជាកន្លងមកនេះ ឯកឧត្តមទទួលបាននូវបទពិសោធន៍ល្អៗជាច្រើន និងបានកត់សម្គាល់ឃើញនូវការរីកចម្រើនរបស់កម្ពុជាលើគ្រប់វិស័យពីមួយឆ្នាំទៅមួយឆ្នាំ។ ជាងនេះទៅទៀត ទំនាក់ទំនងនៃប្រទេសទាំងពីរកាន់តែមានការរីកចម្រើន តាមរយៈការផ្លាស់ប្តូរទស្សនកិច្ចទៅវិញទៅមករបស់ឥស្សរជនជាន់ខ្ពស់នៃប្រទេសទាំងពីរ ទាំងក្នុងវិស័យនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងវិស័យការពារជាតិផងដែរ។ ក្នុងក្របខ័ណ្ឌពហុភាគី ប្រទេសទាំងពីរតែងតែគាំទ្រគ្នាទៅវិញទៅមកនៅលើឆាកអន្តរជាតិ។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណប៉ាគីស្ថានដែលបានទទួលស្គាល់និងភ្ជាប់ទំនាក់ទំនងការទូតជាមួយកម្ពុជានៅឆ្នាំ១៩៥២ គឺតាំងពីមុនកម្ពុជាបានទទួលឯករាជ្យ។ កាលពីឆ្នាំ២០១៧ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** រីករាយបានអញ្ជើញចូលរួមក្នុងការប្រារព្ធខួបលើកទី៦៥ នៃទំនាក់ទំនងការទូតនៃប្រទេសទាំងពីរ នៅទីក្រុងភ្នំពេញ ។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានអរគុណដល់ប៉ាគីស្ថានផងដែរចំពោះការផ្តល់ជំនួយជាសម្ភារៈការិយាល័យ និងផ្តល់វគ្គបណ្តុះបណ្តាលរយៈពេលខ្លីដល់មន្ត្រីកម្ពុជាលើ

ជំនាញការទូត ធនាគារ និងប្រព័ន្ធផ្លូវដែក ហើយសង្ឃឹមថា រដ្ឋាភិបាលប៉ាគីស្ថាននឹងបន្តផ្តល់វគ្គបណ្តុះបណ្តាលនេះបន្ថែមទៀត។ **ឯកឧត្តម ឯកអគ្គរដ្ឋទូត** ក៏បានបញ្ជាក់ជូនថា ប៉ាគីស្ថាននឹងបន្តផ្តល់វគ្គបណ្តុះបណ្តាលជំនាញដល់មន្ត្រីកម្ពុជា រួមទាំងផ្នែកវេជ្ជសាស្ត្រផងដែរ។

ភាគីទាំងពីរ ក៏បានពិភាក្សាអំពីការពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីលើវិស័យជាច្រើនទៀត មានដូចជា ពាណិជ្ជកម្ម វិនិយោគ កសិកម្ម វប្បធម៌ និងទេសចរណ៍ឲ្យកាន់តែរីកចម្រើនសក្តិសមនឹងសក្តានុពលនៃប្រទេសទាំងពីរ។ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានឲ្យដឹងថា ទាំងអ្នកជំនួញ និងទេសចរប៉ាគីស្ថានមានការចាប់អារម្មណ៍កាន់តែខ្លាំងមកលើប្រទេសកម្ពុជា។ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានជំរុញឲ្យពុទ្ធសាសនិករួមទាំងព្រះសង្ឃកម្ពុជាធ្វើទស្សនកិច្ច និងដំណើរធម្មយាត្រានៅតាមបូជនីយដ្ឋានពុទ្ធសាសនាក្នុងប្រទេសប៉ាគីស្ថានដើម្បីជំរុញទំនាក់ទំនងលើវិស័យវប្បធម៌ឲ្យកាន់តែប្រសើរឡើង។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និង**ឯកឧត្តមឯកអគ្គរដ្ឋទូតប៉ាគីស្ថាន** បានរំលឹកអំពីសំណើអញ្ជើញ**សម្តេចតេជោនាយករដ្ឋមន្ត្រី**ទៅបំពេញទស្សនកិច្ចផ្លូវការនៅប៉ាគីស្ថាននាពេលកន្លងមក ដែលត្រូវបានអាក់ខាន និងបានពិភាក្សាអំពីលទ្ធភាពរៀបចំទស្សនកិច្ចនេះក្នុងពេលសមស្របដើម្បីលើកកម្ពស់ទំនាក់ទំនងទ្វេភាគី និងជំរុញកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរតាមរយៈការចុះហត្ថលេខាលើឯកសារមួយចំនួនផងដែរ៕